**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះវិហារ**

# របាយការណ៍ស្តីពី
# ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រះវិហារ

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ បំផុស និងផ្សព្វផ្សាយដល់សាធារណជនឲ្យបានជ្រាបច្បាស់អំពីសមិទ្ធផលដែលលេចធ្លោបំផុតរបស់រដ្ឋបាលខេត្តព្រះវិហារ។

## I.ស្ថានភាពភូមិសាស្ត្រ

ខេត្តព្រះវិហារ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ស្ថិតនៅភាគឧត្តរ នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ ១៩៤ ប.រ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៦៤ មានចម្ងាយផ្លូវប្រវែង ៣០០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញមកកាន់ខេត្តព្រះវិហារ កាត់តាមផ្លូវជាតិលេខ៦A និងផ្លូវជាតិលេខ៦២ មានព្រំប្រទល់ខាងកើតទល់នឹងខេត្តស្ទឹងត្រែង ខាងលិចទល់នឹងខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ខាងត្បូងទល់នឹងខេត្តកំពង់ធំ និងខាងជើងទល់នឹងប្រទេសថៃប្រវែង ១២៩គីឡូម៉ែត្រ និងប្រទេសឡាវប្រវែង ១៤០គីឡូម៉ែត្រ (៩៣គីឡូម៉ែត្រជាប់នឹងស្រុកឆែប និង ៤៧គីឡូម៉ែត្រ ជាប់នឹងស្រុកជាំក្សាន្ត) ព្រមទាំងមានស្ទឹងសែន ១ខ្សែ ដែលមានប្រភពមកពីស្រុកជាំក្សាន្តហូរកាត់ភូមិសាស្ត្រខេត្តព្រះវិហារ មានប្រវែង ២១៣គីឡូម៉ែត្រ និងមានទន្លេមេគង្គហូរកាត់ឃុំកំពង់ស្រឡៅមួយ និងឃុំកំពង់ស្រឡៅពីរ ស្រុកឆែប ខេត្តព្រះវិហារ មានប្រវែង ២៤គីឡូម៉ែត្រ (ជាប់ព្រំដែនប្រទេសឡាវ)។

ខេត្តមានផ្ទៃដីសរុប ១៣.៨២១,៧៦គីឡូម៉ែត្រការ៉េ ប្រជាពលរដ្ឋសរុបទូទាំងខេត្តចំនួន ៦៤,៨៤៦គ្រួសារ ស្មើនឹងចំនួនមនុស្ស ២៦០,៨៦១នាក់ ស្រី ១៣១,៩៦៩នាក់ ដង់ស៊ីតេប្រជាពលរដ្ឋប្រមាណ ១៩នាក់ក្នុង ១គីឡូម៉ែត្រក្រឡា បែកជា ៧ស្រុក ១ក្រុង ៤៩ឃុំ ២សង្កាត់ និង២៣២ភូមិ។

## II.សមិទ្ធផលសំខាន់ៗ

ដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងមានការចូលរួមសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ ប្រជាពលរដ្ឋក្នុងខេត្តទាំងមូល និងពីគ្រប់មជ្ឈដ្ឋាន រដ្ឋបាលខេត្តទទួលបានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសរក្សាបាននូវសុខសន្តិភាព សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមបានល្អប្រសើរ ជាលទ្ធផលរដ្ឋបាលខេត្តសម្រេចបាននូវសមិទ្ធផលសំខាន់ៗរួមមាន ៖

## ១.សមិទ្ធផលឯកជនៈ

រដ្ឋបាលខេត្តបានអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋដែលមានហានិភ័យខ្ពស់ សំដៅកាត់បន្ថយភាពក្រីក្រឲ្យបានជាអតិបរិមា ដែលក្នុងនោះកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រេចបានក្នុងឆ្នាំ២០២២ រួមមាន ៖

- ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ អនុវត្តបានចំនួន ១៧,៣៥២ករណី ស្មើនឹងទឹកប្រាក់សរុប ៨៧៥,០៤០,០០០រៀល (ប្រាំបីរយចិតសិបប្រាំលាន សែសិបពាន់រៀលគត់)
- ជូនគ្រួសារក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ អនុវត្តបានចំនួន ១៤,៩០៦គ្រួសារ ស្មើនឹងទឹកប្រាក់សរុបចំនួន ៧៥,០៩១,៥២០,០០០រៀល (ចិតសិបប្រាំពាន់ កៅសិបមួយលាន ប្រាំរយម្ភៃពាន់រៀលគត់)
- ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងមានសម្ពាធអតិផរណា អនុវត្តបានចំនួន ៥,៩១២គ្រួសារ ស្មើនឹងទឹកប្រាក់ចំនួន ៨០៩,៩៤៧,៦០០រៀល (ប្រាំបីរយប្រាំបួនលាន ប្រាំបួនរយសែសិបប្រាំពីរពាន់ រៀលគត់)។

## ២.សមិទ្ធផលសាធារណៈ ៖

### ក.ការងារគ្រប់គ្រងរដ្ឋបាលៈ

តាមរយៈកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលបានផ្ទេរមុខងារ និងមុខងារផ្តល់សេវា និងបានធ្វើប្រតិភូកម្មជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានធ្វើឲ្យរដ្ឋបាលខេត្តព្រះវិហារកាន់តែមានលទ្ធភាព និងសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ ព្រមទាំងអាចដោះស្រាយបញ្ហាប្រឈមនៅមូលដ្ឋានបានឆាប់រហ័ស និងទាន់ពេលវេលា។ អង្គភាព និងការិយាល័យច្រកចេញ ចូលតែមួយខេត្ត ក្រុង ស្រុកបានដើរតួនាទីសំខាន់នៅក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានក្នុងរយៈពេល ៥ឆ្នាំ(២០១៨-២០២២) ហើយក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះអង្គភាពច្រកចេញ ចូលតែមួយខេត្តបានផ្តល់សេវាជូនប្រជាពលរដ្ឋសរុបចំនួន ៣៧,៦៣៧សេវា និងទទួលបានចំណូលសរុបចំនួន ៥,០៥៥,៦៦១,០០០រៀល។

### ខ.ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត បានសហការជាមួយកម្លាំងទទួលទិសសមរភូមិមុខ និងកម្លាំងឈរជើងតាមបណ្តោយព្រំដែន បានធ្វើឲ្យសភាពការណ៍តាមបណ្តោយព្រំដែនកម្ពុជា-ថៃ-ឡាវមានសភាពស្ងប់ស្ងាត់ល្អប្រសើរ។ ដោយឡែកសភាពការណ៍សណ្តាប់ធ្នាប់ផ្ទៃក្នុង តាមរយៈការអនុវត្តគោលនយោបាយ " **ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព** " បានធ្វើឲ្យបទល្មើសមានការថយចុះ និងជានាបានសន្តិសុខរបៀបរៀបរយល្អ ជាក់ស្តែងនៅក្នុងឆ្នាំ២០២២ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងការត្រៀមលក្ខណៈសម្រាប់កិច្ចការពារក្នុងដំណើរការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខ។

***គ.វិស័យកសិកម្ម:***

ខេត្តមានវិសាលភាពផ្ទៃដីធំទូលាយ ដែនដីប្រកបដោយជីវជាតិ និងជាប្រភពដ៏ប្រសើរសម្រាប់វិស័យកសិកម្មដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋប្រមាណជាង៨០% នៅទូទាំងខេត្ត ដែលមានមុខរបរចម្បងលើវិស័យនេះ។ ខេត្តមានសក្តានុពលធ្វើកសិកម្មសរីរាង្គ និងជាប្រភពផ្គត់ផ្គង់កសិផលសរីរាង្គច្រើនជាងគេ និងនាំចេញទៅកាន់ទីផ្សារអន្តរជាតិឈានមុខគេ។ ជាលទ្ធផលក្នុងឆ្នាំ២០២២ ការដាំដុះស្រូវរដូវវស្សាអនុវត្តបានចំនួន ៩៩,១២០ហិកតា លើផែនការ ៩១,២០០ហិកតា ដែលផ្ទៃដីប្រមូលផលសរុប ៩៤,០៦៣ហិកតា ផ្ទៃដីប្រមូលផលបាន ៩៤,០៦៣ហិកតា ស្មើនឹង ១០០%ទទួលបានបរិមាណផលចំនួន ២៨៣,៧៤៣តោន និងទិន្នផលមធ្យម ៣.០១៧តោន/ហិកតា។ ដោយឡែកចំពោះការបង្កបង្កើនផលដំណាំរួមផ្សំ ដំណាំកសិឧស្សាហកម្ម និងឈើហូបផ្លែអនុវត្តបានសរុបចំនួន ៦៣,៤៣៤ហិកតា ស្មើនឹង ៩០.៨៧% នៃផែនការ ៦៩,៨០៥ហិកតា ក្នុងនោះ ៖

- ដំណាំរួមផ្សំ និងសាកវប្បកម្ម អនុវត្តបាន ៧៩០ហិកតា ស្មើនឹង ៣៥.៣២%
- ដំណាសាកវប្បកម្ម និងដំណាំហូបផ្លែរយៈពេលវែង អនុវត្តបាន ៧,២០១ហិកតា ស្មើនឹង ៧២.៥៤%
- ដំណាំឧស្សាហកម្ម អនុវត្តបាន ៣៨,៣១៨ហិកតា ស្មើនឹង ៩៦.៦៨%
- ដំណាំឧស្សាហកម្មរយៈពេលវែង អនុវត្តបាន១៧,១២៥ហិកតាស្មើនឹង៩៥.១០%។

បច្ចុប្បន្ននេះខេត្តព្រះវិហារមានសហគមន៍កសិកម្មសរុបចំនួន ៤៣សហគមន៍ មានសមាជិកសរុបប្រមាណមួយម៉ឺនគ្រួសារ ដោយមានការសម្របសម្រួលពីការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម និងត្រូវបានចុះបញ្ជីទទួលជាស្គាល់ជាសហគមន៍កសិកម្មស្របច្បាប់ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ ដែលមុខរបរសំខាន់ៗរបស់សហគមន៍កសិកម្មផ្តោតលើការធ្វើឥណទានកសិកម្មខ្នាតតូច ផ្គត់ផ្គង់សម្ភារកសិកម្ម ធ្វើរបរទីផ្សារ និងបានចុះកិច្ចសន្យាទិញលក់ផលិតផលសរីរាង្គដូចជា ស្រូវសរីរាង្គ ដំឡូងមីសរីរាង្គ និងគ្រាប់ស្វាយចន្ទីសរីរាង្គ។

***ឃ.វិស័យធនធានទឹក និងឧតុនិយម:***

វិស័យនេះក៏ជាផ្នែកមួយសំខាន់សម្រាប់កិច្ចការងារកសិកម្ម ការផ្គត់ផ្គង់ទឹក និងបម្រើដល់វិស័យទេសចរណ៍ផងដែរ ដោយបានកសាងប្រព័ន្ធធារាសាស្ត្ររួចរាល់មានចំនួន៣១, ជួសជុល និងថែទាំប្រចាំមានចំនួន ០៧គម្រោង និងជាពិសេសទំនប់អាងទឹករក្សាដែលជាប្រភេទអាងទឹកមួយក្នុងចំណោមអាងទឹក២(មួយទៀតគឺដងកាំបិត) ដែលយកប្រភពទឹកពីស្ទឹងសែន ដែលទំនប់ខាងឆ្វេងស្ថិតនៅក្នុងឃុំពុទ្រា ស្រុកជ័យសែន និងទំនប់ខាងស្តាំស្ថិតនៅក្នុងឃុំរក្សា ស្រុករវៀង ខេត្តព្រះវិហារ សូមបញ្ជាក់ជូនថា ស្ទឹងសែនជាស្ទឹងដែលមានតំបន់ផ្ទៃរងទឹកភ្លៀងធំជាងគេក្នុងចំណោមបណ្តាស្ទឹងដទៃទៀតរបស់កម្ពុជាលាតសន្ធឹងលើផ្ទៃដី១៣,៦៥៣ម៉ែត្រការ៉េ។ ទំនប់អាងទឹករក្សាមានលទ្ធភាពរក្សាទឹកទុកក្នុងរដូវវស្សាបានចំនួនប្រមាណ ២៥៦,៩លានម៉ែត្រគូប និងអាចផ្គត់ផ្គង់ទឹកស្រោចស្របបង្កបង្កើនផលិតផលកសិកម្មលើផ្ទៃដីទំហំប្រមាណ ១៤៣.៣២៣ហិកតានៅរដូវវស្សា និងប្រមាណ ២២.៨៧៨ហិកតានៅរដូវប្រាំង។ ទំនប់អាងទឹករក្សា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងអាចផ្គត់ផ្គង់ទឹកស្អាតតាមតំបន់មួយចំនួននៅផ្នែកខាងក្រោម។

*ង.វិស័យហេដ្ឋារចនាសម្ព័ន្ធ:*

ខេត្តបានបន្តការស្តារហេដ្ឋារចនាសម្ព័ន្ធដោយផ្តោតសំខាន់លើការងារកសាង ជួសជុល ថែទាំផ្លូវជាតិ ផ្លូវខេត្ត និងបន្តកសាងផ្លូវខេត្ត ផ្លូវជនបទឲ្យមានគុណភាពខ្ពស់ក្នុងគោលបំណងតភ្ជាប់បណ្តាញផ្លូវពីទីរួមខេត្តទៅស្រុក ពីស្រុកទៅស្រុក និងពីស្រុកទៅឃុំ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចរបស់ខេត្ត។ ក្រៅពីនេះ បានធ្វើការជួសជុល និងថែទាំជាប្រចាំផ្លូវខេត្ត ក្រុង ស្រុក តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរសាធារណការ និង ដឹកជញ្ជូន រីឯហេដ្ឋារចនាសម្ព័ន្ធផ្លូវនៅតាមឃុំ-សង្កាត់ ត្រូវបានកសាងបន្ថែមតាមរយៈការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ ចំពោះសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០២២ រួមមាន ៖ ការជួសជុលផ្លូវក្រាលក្រួសក្រហម, ផ្លូវក្រាលកៅស៊ូDBST និងផ្លូវចាក់បេតុងចំនួន ១០ខ្សែប្រវែង ៨៩,០៩៥ម៉ែត្រ ដាក់លូភ្លោះ ៣៤កន្លែង និងលូទោល១,០២២កន្លែង, ការស្ថាបនាផ្លូវបេតុង និងទីរួមខេត្តព្រះវិហារប្រវែង ៨៩១ម៉ែត្រ, ការជួសជុលផ្លូវក្រាលកៅស៊ូAC, ការសាងសង់រង្វង់មូលរូបសំណាកគោបុះទី៥ ប្រាសាទព្រះវិហារនៅផ្លូវជាតិលេខ៦២ ឃុំស្រអែម ស្រុកជាំក្សាន្ត, ការរៀបចំកែសម្ផស្សសួនច្បារ និងរង្វង់មូលប្រាសាទព្រះវិហារក្នុងបរិវេណសាលាខេត្ត និងសមិទ្ធផលដែលលេចឡើងនៅជាប់ព្រំដែនឡានគីវេទិកាប្រណាំងទូកមិត្តភាពរវាងព្រះវិហារ និងចម្ប៉ាសាក់ ដែលរួមមាន ៖ ស្នាក់ការប្រណាំងទូក១, ការចាក់បេតុងប្រាំងទន្លេប្រវែង ៥0ម៉ែត្រ, រោងទូក ១កន្លែង, បន្ទប់ទឹក, សួនច្បារ, កន្លែងបួងសួង ២កន្លែង និងរបងព័ទ្ធជុំវិញ ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងសប្បុរសជននានា។

*ច.វិស័យអប់រំ:*

ខេត្តមានអាគារសិក្សាគ្រប់កម្រិតចំនួន ៤១០កន្លែង ក្នុងនោះ ៖ មានវិទ្យាល័យ ១៩កន្លែង, អនុវិទ្យាល័យ ៤៧កន្លែង, បឋមសិក្សា ២២៨កន្លែង និងមត្តេយ្យសិក្សា ១១៦កន្លែង មានបុគ្គលិកសិក្សា ២,៥៨៦នាក់ ស្រី១,២៤០នាក់ ក្នុងនោះសាលារៀនដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** សរុបចំនួន ១១៦ខ្នង។

រីឯការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០២១-២០២២ នៅទូទាំងខេត្តព្រះវិហារបេក្ខជនដាក់ពាក្យប្រឡងចំនួន ១,៦៧៧នាក់ ស្រី ៩២០នាក់, បេក្ខជនមកប្រឡងសរុប ១,៦៥៥នាក់ ស្រី ៩០៩នាក់ និងទទួលបានលទ្ធផលជាប់សរុប ១,៣00នាក់ ស្រី ៧៦៤នាក់ ស្មើនឹង ៧៨,៥៥% ក្នុងនោះ ៖ សិស្សនិទ្ទេសA ចំនួន ៤នាក់ ស្រី ៣នាក់, និទ្ទេសB ចំនួន ៥៨នាក់ណ ស្រី ៤៥នាក់, និទ្ទេសC ចំនួន ២៥៧នាក់ ស្រី ១៥០នាក់, និទ្ទេសD ចំនួន ៥២៤នាក់ ស្រី ៣១៩នាក់ និងនិទ្ទេសE ចំនួន ៤៥៧នាក់ ស្រី ២៤៧នាក់។

### ឆ.វិស័យរ៉ែ និងថាមពល:

ខេត្តព្រះវិហារសម្បូរទៅដោយធនធានរ៉ែរួមមាន ៖ រ៉ែដែក រ៉ែស្ពាន់ រ៉ែមាស រ៉ែប្រេងកាត និងរ៉ែលោហៈផ្សេងៗទៀតដែលគ្រប់ដណ្តប់ស្ទើរទូទាំងខេត្ត ហើយមកទល់ពេលនេះ មានក្រុមហ៊ុនចំនួន ២២ក្រុមហ៊ុន ដែលបានកំពុងធ្វើអាជីវកម្ម និងសិក្សាស្រាវជ្រាវក្នុងនោះមាន ៖

-អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមានចំនួន ០៣ក្រុមហ៊ុន

-អាជ្ញាបណ្ណសិក្សាស្រាវជ្រាវធនធានរ៉ែមានចំនួន ០៩ក្រុមហ៊ុន

-អាជ្ញាបណ្ណអណ្តូងរ៉ែ បើកនិងការដ្ឋានវាយថ្មមានចំនួន ១០ក្រុមហ៊ុន

ដោយឡែកចំពោះការផ្គត់ផ្គង់អគ្គីសនី ដោយមានកិច្ចសហប្រតិបត្តិការជាមួយខេត្តចម្ប៉ាសាក់ប្រទេសឡាវ បានភ្ជាប់បណ្តាញពីខេត្តស្ទឹងត្រែង និងពង្រីកបណ្តាញអគ្គិសនីប្រើប្រាស់បានទូទាំងខេត្ត។

### ជ.វិស័យសុខាភិបាល:

ខេត្តមានមូលដ្ឋានផ្តល់សេវាសាធារណៈចំនួន ៤៨កន្លែង ក្នុងនោះ មន្ទីរពេទ្យបង្អែកខេត្តចំនួន ០១កន្លែង, មន្ទីរពេទ្យបង្អែកស្រុកចំនួន ០១កន្លែង, មណ្ឌលសុខភាពចំនួន ៣០កន្លែង និងប៉ុស្តិ៍សុខភាពចំនួន ១៦កន្លែង មានបុគ្គលិកបម្រើការងារសរុប ៥៣៩នាក់ ពេទ្យធ្មបមធ្យម ១០៦នាក់ និងពេទ្យធ្មបបឋម ៩៥នាក់ ដោយបានទទួលពិនិត្យ និងថែទាំព្យាបាលជំងឺជូនប្រជាពលរដ្ឋទៅលើផ្នែកសុខភាពបន្តពូជយុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ, ផ្នែកប្រយុទ្ធទៅនឹងជំងឺឆ្លង (អេដស៍, របេង, គ្រុនចាញ់, គ្រុនឈាម) ផ្នែកប្រយុទ្ធទៅនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតរួមមាន ៖ សុខភាពភ្នែក, សុខភាពផ្លូវចិត្ត និងគាំពារគ្រឿងញៀន, សុខភាពមាត់-ធ្មេញ និងជំងឺរាំរ៉ៃផ្សេងៗ មិនត្រឹមតែប៉ុណ្ណោះតាមរយៈកិច្ចសហការគាំទ្រពីសំណាក់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រជាពលរដ្ឋជាច្រើនបានទទួលពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃតាម នៅតាមបណ្តាក្រុងស្រុកទូទាំងខេត្តរួមមាន ជំងឺទូទៅ កុមារ ជំងឺភ្នែក មាត់-ធ្មេញ និងវះកាត់តូច-ធំផ្សេងផងដែរៗ។ រីឯការងារបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ រដ្ឋបាលខេត្តបានប្រើប្រាស់កម្លាំងសរុប និងវិធានការសរុបចូលរួមពេញទំហឹងក្នុងការអនុវត្តនូវវិធានការនានារបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** រហូតអាចគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ និងបើកដំណើរការប្រទេសឡើងវិញ។ បច្ចុប្បន្នក្រុមការងាររបស់មន្ទីរសុខាភិបាលបាននឹងកំពុងបន្តចាក់វ៉ាក់សាំងដូសជំរុញ (ដូសទី៤ ដូសទី៥ និងដូសទី៦) ពិសេសបានសហការជាមួយអាជ្ញាធរក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងការជំរុញចុះចាក់វ៉ាក់សាំងតាមគោលដៅទីប្រជុំជន សាលារៀន តំបន់ដាច់ស្រយាល និងតាមខ្នងផ្ទះ។

## ឈ.វិស័យទេសចរណ៍:

វិស័យនេះក៏មានសក្តានុពលនៅក្នុងខេត្តផងដែរ ដែលខេត្តព្រះវិហារគឺជាខេត្តចាត់ក្នុងលំដាប់ថ្នាក់ទី២ នៃខេត្តសម្បូរទៅដោយប្រាង្គប្រាសាទបុរាណនាសម័យអង្គរ បន្ទាប់ពីខេត្តសៀមរាប និងជាខេត្តដែលសេសសល់ព្រៃឈើមានលក្ខណៈធម្មជាតិ ដែលកំពុងត្រូវបានអភិរក្សការពារពីគ្រប់ភាគីពាក់ព័ន្ធដោយស្មារតីទទួលខុសត្រូវក្នុងការរក្សាឲ្យបាននូវភាពគង់វង្សយូរអង្វែង។ ជាមួយគ្នានេះគោលដៅទេសចរណ៍សំខាន់ៗ ដែលភ្ញៀវទេសចរណ៍មកទស្សនាកម្សាន្តមានចំនួន ២៧កន្លែង ក្នុងនោះរមណីយដ្ឋានប្រវត្តិសាស្ត្រ និងធម្មជាតិ ០៥កន្លែង, សារៈមន្ទីរ ០១កន្លែង, សហគមន៍ ១០កន្លែង វត្តគោលដៅទេសចរណ៍ ៣កន្លែង និងកន្លែងសក្តានុពលទេសចរណ៍ ៨កន្លែង។ រយៈពេល ០៥ឆ្នាំ ខេត្តទទួលបានភ្ញៀវទេសចរសរុបចំនួន ២,២១៥,៨៥៦នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិ ចំនួន ២,០៥៦,១០៥នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន ១៥៩,៧៥១នាក់ ដែលក្នុងនោះឆ្នាំ២០២២ ខេត្តទទួលបានភ្ញៀវទេសចរសរុបចំនួន ៣៣៩,៦៨៦នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិមានចំនួន ៣២៩,៩៩៣នាក់ ភ្ញៀវទេសចរអន្តរជាតិមានចំនួន ៩,៦៩៣នាក់។

រីឯស្ថិតិអាជីវកម្មទេសចរណ៍ខេត្តមានសណ្ឋាគារចំនួន ៤កន្លែង ស្មើនឹង ១៨៥បន្ទប់ មានបុគ្គលិក ៥៥នាក់ ស្រី ២៦នាក់, ម៉ូតែលមានចំនួន ៣កន្លែង ស្មើនឹង ៤០បន្ទប់ មានបុគ្គលិក ១៦នាក់ ស្រី ១១នាក់ ផ្ទះភ្ញៀវមានចំនួន ៣៨កន្លែង ស្មើនឹង ៥០៦បន្ទប់ មានបុគ្គលិកចំនួន ១១១នាក់ ស្រី ៧០នាក់, មគ្គុទ្ទេសក៏ទេសចរសរុបចំនួន ១១នាក់ ស្រី ០៥នាក់, ភោជនីយដ្ឋាន-អាហារដ្ឋាន ចំនួន ៦៦កន្លែង ចំនួន ២.៧៨២កៅអី មានបុគ្គលិក ២០៨នាក់ ស្រី ១៥៦នាក់, បៀរហ្គាឌិន (ពុំមាន), ខារ៉ាអូខេចំនួន ១៩កន្លែង ស្មើនឹង ៧៨បន្ទប់ មានបុគ្គលិកចំនួន ៧៩នាក់ ស្រី ៥៧នាក់ ម៉ាស្សាសុខភាពចំនួន ០៦កន្លែង មាន ៣០គ្រែ មានបុគ្គលិក ៣១នាក់ ស្រី ២២នាក់។

## ញ.វិស័យព័ត៌មាន:

ដោយមានការវិវត្តន៍ផ្នែកសោតទស្សន៍ ផ្នែកបច្ចេកវិទ្យាព័ត៌មានរួមជាមួយស្ថានភាពនយោបាយប្រកបដោយសុខសន្តិភាព និងកិច្ចទំនាក់ទំនងជាសកលលើឆាកអន្តរជាតិ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលបានការគាំទ្រយ៉ាងសកម្មពីបណ្តាប្រទេសក្នុងតំបន់ ក៏ដូចជានៅក្នុងពិភពលោក ដែលជំរុញឲ្យព្រះរាជាណាចក្រកម្ពុជាមានកំណើនសេដ្ឋកិច្ច ការវិវត្តន៍លើគ្រប់វិស័យ ក្នុងនោះវិស័យព័ត៌មានបានរួមចំណែកយ៉ាងសកម្ម និងបានដើរតួនាទីជាស្ពានភ្ជាប់រវាងរាជរដ្ឋាភិបាលជាមួយនឹងប្រជាពលរដ្ឋ ដែលឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្នរបស់ប្រទេសជាតិជូនប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ក៏ដូចជាប្រជាជាតិលើពិភពលោកបានស្គាល់កាន់តែច្បាស់អំពីកម្ពុជា។ ដោយឡែកនៅក្នុងខេត្តវិស័យព័ត៌មានបាននឹងកំពុងខិតខំបំពេញការងារតាមជំនាញរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវ និងការច្នៃប្រឌិតខ្ពស់។ សេរីភាពក្នុងការទទួលបានព័ត៌មាន និងការបញ្ចេញមតិសម្រាប់ខេត្តព្រះវិហារត្រូវបានគោរពយ៉ាងម៉ត់ចត់។ បច្ចុប្បន្នក្នុងខេត្តមានស្ថានីយវិទ្យុFM ចំនួន ០៥ស្ថានីយ៍ទូរទស្សន៍ខ្សែកាប ០២ស្ថានីយ៍ និងមានភ្នាក់ងារធ្វើការផ្សព្វផ្សាយព័ត៌មានតាមរយៈការបោះពុម្ពជាកាសែតទស្សនាវដ្តី ហើយអ្នកសារព័ត៌មានចំនួន ៣២នាក់ ក្នុងនោះចែកជាពីរគឺ ភ្នាក់ងារសារព័ត៌មានរបស់ទូរទស្សន៍ឯកជនមានចំនួន១៣ទូរទស្សន៍ និងគេហទំព័រមានចំនួន ១៣អង្គភាព ដែលកំពុងបំពេញការងារយកព័ត៌មានក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។

## ដ.វិស័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី:

ការងាររដ្ឋបាលដីធ្លីបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការចុះបញ្ជីដីធ្លី ការទប់ស្កាត់ និងការដោះស្រាយវិវាទដីធ្លីដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងទាញយកផលប្រយោជន៍ពីការប្រើប្រាស់ដី។ ក្នុងរយៈពេល ៥ឆ្នាំកន្លងមក គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ រដ្ឋបាលខេត្តសម្រេចបានរួមមាន ៖

- **ការចុះបញ្ជីដី**
  - មានលក្ខណៈជាប្រព័ន្ធបាន ២៥,៣៥២ប័ណ្ណ ស្មើនឹងផ្ទៃដីទំហំ ២២០,៥៤៣ហិកតា
  - មានលក្ខណៈដាច់ដោយដុំបាន ៤២៩ប័ណ្ណ ស្មើនឹង ១៥១,៦០៤,៦៣៧ម៉ែត្រការ៉េ
  - ការចុះបញ្ជីដីរដ្ឋសម្រេចបាន ១៨ប័ណ្ណ លើផ្ទៃដីទំហំ ៤,៥០៧.០៧ហិកតា ចំនួន ០៦ក្រុមហ៊ុន
- **ការដោះស្រាយវិវាទដីធ្លី**

ទទួលបានពាក្យបណ្តឹងសរុបចំនួន ៣៤ករណីជាបណ្តឹងក្រៅយន្តការគណៈកម្មការសុរិយោដី ក្នុងនោះ ដោះស្រាយបញ្ចប់បានចំនួន ១៣ករណី កំពុងដោះស្រាយចំនួន ១១ករណី និងបង្វែរសំណុំរឿងគណៈកម្មការរដ្ឋបាលទៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់សុំចូលជាគណៈកម្មការសុរិយោដីចំនួន ១០ករណី។

# III.ទិសដៅការងារបន្ត

- បន្តអនុវត្តគោលនយោបាយ **"ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"**
- បន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ សំដៅលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍលើគ្រប់វិស័យក្នុងខេត្ត
- បន្តពង្រឹងធនធានមនុស្ស និងគុណភាពអប់រំ ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- បន្តពង្រឹង និងជំរុញការអនុវត្តកសិកម្មតាមកិច្ចសន្យាចំពោះផលិតផលសរីរាង្គ និងជំរុញប្រជាកសិករខិតខំបង្កបង្កើនផល និងរក្សាគុណភាព
- ខិតខំប្រែក្លាយជាខេត្តកសិកម្មសរីរាង្គ
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- បន្តខិតខំរៀបចំតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងវប្បធម៌
- បន្តអនុវត្តកម្មវិធីគាំពារសង្គមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។